អង្គរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ គួរធ្វើបុណ្យរំឭករាល់ឆ្នាំនៅថ្ងៃ២៣តុលា ព្រោះជាថ្ងៃដែលគ្រប់ភាគីខ្មែររួបរួមគ្នាធ្វើសន្ធិសញ្ញាសន្តិភាពនៅទីក្រុងប៉ារីស ។

website ៖ www.hoksavann.org

*ថ្ងៃទី៣ កញ្ញា ២០០៩*



*ពេលនេះយើងនិយាយអំពីព្រឹត្តិការណ៍ខ្មែរក្នុងសតវត្សរ៍ទី២០ ជាពិសេសចាប់ពីឆ្នាំ១៩៧០ រហូតមកដល់បច្ចុប្បន្ននេះ ។ ព្រឹត្តិការណ៍ថ្ងៃ១៨ មីនា ១៩៧០ រហូតមកដល់បច្ចុប្បន្នមានរយៈពេលជាង៣ទសវត្សរ៍ ។ សង្គ្រាម៥ឆ្នាំ របបវាលពិឃាត ការឈ្លានពានពីបរទេស ព្រឹត្តិការណ៍ទាំងនេះបញ្ជាក់ថា ខ្មែរនិងខ្មែរបានបែកបាក់សាមគ្គី ហើយព្រឹត្តិការណ៍ទាំងនេះពុំមែនបង្កើតឡើងដោយខ្មែរនិងខ្មែរខ្លួនឯងប៉ុណ្ណោះទេ តែមានការជម្រុញនិងការជួយឧបត្ថម្ភពីបរទេស ជាពិសេសពីមហាអំណាច ដែលពេលនោះមានការប្រណាំងប្រជែងគ្នារវាងមនោគមវិជ្ជាពីរ គឺមនោគមវិជ្ជាសេរី និងមនោគមវិជ្ជាកុម្មុយនិស្ត ។ បន្ថែមពីលើនេះទៀត គឺមហិច្ឆិតារបស់ប្រទេសជិតខាង ដែលចង់បានទឹកដីខ្មែរ និងផែនការសហព័ន្ធកុម្មុយនិស្តឥណ្ឌូចិន ។*

*ប៉ុន្តែបរទេសចង់បានអ្វីពីខ្មែរវាជារឿងមួយ រឿងសំខាន់នៅលើខ្មែរខ្លួនឯង ហេតុអ្វីបានជាមិនរករូបមន្តកុំឲ្យខ្មែរនិងខ្មែរបែកបាក់សាមគ្គីគ្នា ឬមានឯកភាពជាតិ កុំឲ្យបរទេសលូកដៃចូលមកបាន ? ។*

*ត្រង់នេះកុំបន្ទោសខ្មែរជំនាន់ដើម ស្តេចនិងស្តេចទាស់គ្នា មួយទៅពឹង*

សៀម មួយទៅពឹងយួនទៀយ នៅសតវត្សរ៍ទី២០នេះ ជាពិសេសចាប់ពីឆ្នាំ ១៩៧០មក ក៏មិនខុសគ្នាពីសតវត្សរ៍មុនៗដែរ គឺស្តេចក្តីវាស្រ្តក្តី មួយក្រុមទៅពឹងសៀម មួយក្រុមទៅពឹងយួនដូចតែគ្នា ។

ការពឹងបរទេសមកកំទេចខ្មែរគ្នាឯងនេះ ជាគ្រោះថ្នាក់ធ្ងន់ធ្ងរណាស់ដល់ប្រទេសខ្លួន ។ ជំទាស់គ្នាតាមផ្លូវនយោបាយនេះ បានធ្វើឲ្យប្រជាពលរដ្ឋខ្មែររងទុក្ខវេទនាយ៉ាងក្រៃលែងគួរឲ្យរន្ធត់ រចនាសម្ព័ន្ធរបស់ប្រទេសក៏ត្រូវវិនាសខ្ទេចខ្ទី ។ ព្រះរាជាណាចក្រខ្មែរកាលពីសតវត្សរ៍មុន ជាពិសេសសម័យមហានគរ ជាមហាអំណាច មានទឹកដីធំទូលំទូលាយ មានអរិយធម៌ខ្ពង់ខ្ពស់ ។ ឥឡូវទឹកដីនៅសល់តែ៣០% ត្រូវបាត់បង់៧០% ហើយទឹកដីដែលនៅសេសសល់នេះ នឹងត្រូវបាត់បង់ជាបន្តទៅទៀត បើខ្មែរមិនរួបរួមគ្នាទេ ។

ដោយឃើញព្រឹត្តិការណ៍គួរឲ្យអាណោចអាធម្មនៃប្រជាពលរដ្ឋខ្មែរ ទើបអន្តរជាតិខំជួយខ្នះខ្នែងធ្វើយ៉ាងណា ដើម្បីឲ្យខ្មែរបានសុខសន្តិភាព និងការបង្រួបបង្រួមជាតិឡើងវិញ ព្រោះមហាអំណាចទាំងនោះមិនអាចទាញយកប្រយោជន៍អ្វីពីខ្មែរទៀតឡើយ ។ ដោយការជំរុញពីអន្តរជាតិផង ទើបខ្មែរនិងខ្មែរចតុភាគីព្រមព្រៀងឈប់ច្បាំងគ្នា ។ កិច្ចព្រមព្រៀងធ្វើសន្និសញ្ញាសន្តិភាពនៅទីក្រុងប៉ារីសប្រទេសបារាំង នៅថ្ងៃ២៣ តុលា ១៩៩១ ភាគីខ្មែរទាំងបួនគឺ រដ្ឋាភិបាលរដ្ឋកម្ពុជា, ហ៊្វុនស៊ិនប៉ិច, រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ និងកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) ។ ក្នុងកិច្ចព្រមព្រៀងនោះ មានចុះហត្ថលេខា១៩ប្រទេស ហើយខ្លឹមសារនៃកិច្ចព្រមព្រៀង ដែលមានអង្គការសហប្រជាជាតិជាអ្នកចាត់ចែង គឺត្រូវដកកងទ័ពបរទេសទាំងអស់ចេញពីប្រទេសកម្ពុជា, ត្រូវដកអាវុធចេញពីគ្រប់ភាគីខ្មែរ, ត្រូវរៀបចំបោះឆ្នោតដោយសេរីនិងយុត្តិធម៌, ត្រូវកសាងប្រទេសកម្ពុជាឡើងវិញ ។

នៅឆ្នាំ១៩៩៣ កិច្ចព្រមព្រៀងនេះបានចេញជាលទ្ធផល គឺបង្កើតបានរដ្ឋធម្មនុញ្ញនៃរាជាណាចក្រកម្ពុជា អនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស មានព្រះមហាក្សត្រសោយរាជ្យតែមិនកាន់អំណាច ។ លទ្ធផលមួយទៀតគឺការបោះឆ្នោតក្រោមកិច្ចចាត់ចែងរបស់អង្គការសហប្រជាជាតិ ដែលហៅថាអ៊ុនតាក់ ។ លទ្ធផលនៃការបោះឆ្នោតនោះ គណបក្សហ៊្វុនស៊ិនប៉ិចរបស់សម្តេច

ចនរោត្តម-សីហនុ មានប្រៀបជាងគណបក្សពីរទៀត គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា ។ ឯគណបក្សកម្ពុជាប្រជាធិបតេយ្យរបស់ខ្មែរក្រហម មិនបានចូលរួមបោះឆ្នោតឡើយ ។ លទ្ធផលដែលគណបក្សហ្វ៊ុនស៊ិនប៉ិចបានឈ្នះឆ្នោតនោះ ជាការឆ្លុះបញ្ចាំងយ៉ាងច្បាស់ថា ពលរដ្ឋខ្មែរស្រឡាញ់របបសេរី ហើយស្អប់ខ្ពើមរបបកុម្មុយនិស្ត ទោះបីរបបកុម្មុយនិស្តបែបចិនរបស់ប៉ុល-ពតក្ដី របៀបយួនកុម្មុយនិស្តក្ដី ។ ប៉ុន្ដែពលរដ្ឋខ្មែរបានខកចិត្ត ដោយគណបក្សហ្វ៊ុនស៊ិនប៉ិចបានបែរអើជាមួយគណ-បក្សប្រជាជនកម្ពុជាដដែល ដូច្នេះពលរដ្ឋខ្មែររស់ផ្លូវជំរើស អាណត្តិក្រោយខ្មែរភាគច្រើននាំគ្នាបោះឆ្នោតឲ្យគណបក្សប្រជាជនវិញទៅ ព្រោះមើលឃើញថា គណបក្សនេះពីដើមជាគណបក្សកុម្មុយនិស្តរបស់យួនហាណូយ តែឥឡូវបានកែប្រែបន្តិចម្តងៗចេញពីកុម្មុយនិស្ត ។ ប៉ុន្តែអ្នកនយោបាយខ្មែរនៅតែព្រួយបារម្ភអំពីឥទ្ធិពលរបស់យួនហាណូយមកពីគណបក្សប្រជាជនកម្ពុជា ដោយគេមើលឃើញអំពីសន្ធិសញ្ញាបំពេញបន្ថែម ខ្លាចក្រែងបាត់បង់ទឹកដី អន្តោប្រវេសន៍វៀតណាមចូលមកកម្ពុជាដោយខុសច្បាប់គ្មានដោះស្រាយទាល់តែសោះ ថែមទាំងជួលសំរួលឲ្យរស់នៅបានសុខស្រួលទៀតផង ។ ផ្ទុយទៅវិញ បងប្អូនខ្មែរកម្ពុជាក្រោមដែលមករស់នៅប្រទេសកម្ពុជា មិនត្រឹមតែមិនជួយសម្រួលទេ ថែមទាំងបង្ករឿងហេតុ ដូចករណីលោកទឹម-សាខនជាដើម ។ ភស្តុតាងមួយទៀត ត្រង់គណបក្សប្រជាជនកម្ពុជានៅតែរំឭកថ្ងៃ៧មករា១៩៧៩ ដែលវៀតណាមចូលដេញរបបខ្មែរក្រហមចេញពីអំណាច ថាជាថ្ងៃឲ្យកំណើតខ្មែរ បើកុំតែមានថ្ងៃនេះ កុំអីគ្មានយើងសព្វថ្ងៃនេះទេ ហើយថែមទាំងបានចាត់ទុកជាថ្ងៃបុណ្យជាតិទៀតផង ។ យើងយល់ថា បើគណបក្សប្រជាជនកម្ពុជាធ្វើយ៉ាងណាឲ្យចេញផុតពីអំណាចវៀតណាម ពលរដ្ឋខ្មែរនឹងបោះឆ្នោតឲ្យគណបក្សប្រជាជនកម្ពុជាកាន់តែច្រើនឡើងថែមទៀត ។ មានប្រទេសខ្លះ គេសុខចិត្តដកខ្លួនគេចេញឲ្យអ្នកដទៃធ្វើការវិញ ដើម្បីចេញឲ្យផុតពីឥទ្ធិពលរបស់បរទេសមកលើប្រទេសរបស់ខ្លួន ។

តាមការទាញយកព្រឹត្តិការណ៍ខ្មែរមកបញ្ជាក់ប៉ុណ្ណោះបញ្ជាក់ថា ថ្ងៃ២៣តុ-លាជាថ្ងៃដែលខ្មែរគ្រប់ភាគីជម្លោះខ្មែរ បានព្រមព្រៀងជានានឹងគ្នា បន្ទាប់ពីមា

នវិវាទនឹងគ្នាជាងពីរទសវត្សរ៍មក ។ ជាពិសេសការព្រមព្រៀងគ្នានេះ មានការធានានិងការឱបត្ថម្ភពីអង្គការសហប្រជាជាតិផង ។ ដូច្នេះគួរយកថ្ងៃ២៣តុលានេះជាថ្ងៃបុណ្យជាតិ ត្រូវធ្វើបុណ្យរំឭករាល់ឆ្នាំ ព្រោះមិនមែនត្រឹមតែជាថ្ងៃដែលខ្មែរនិងខ្មែររួបរួមគ្នាដាក់អាវុធ ហើយសុខចិត្តដោះស្រាយបញ្ហាប្រទេសរបស់ខ្លួនដោយសន្តិវិធីប៉ុណ្ណោះទេ ថែមទាំងតម្រូវឲ្យកងទ័ពបរទេសដកចេញពីប្រទេសកម្ពុជាឲ្យខ្មែរបានឯករាជ្យ ដោះស្រាយបញ្ហាខ្លួនដោយខ្លួនឯងទៀតផង ។ ចំណែកថ្ងៃ៧មករា១៩៧៩វិញ ជាថ្ងៃដែលខ្មែរនៅបែកបាក់គ្នា ដោយចោទគ្នាទៅវិញទៅមក ដោយក្រុមមួយថា វៀតណាមចូលមកជួយរំដោះប្រជាពលរដ្ឋខ្មែរ ឲ្យចេញផុតពីរបបខ្មែរក្រហម មួយក្រុមទៀតរួមទាំងអង្គការសហប្រជាជាតិផងថា វៀតណាមចូលមកឈ្លានពានប្រទេសកម្ពុជា ។ ការយកថ្ងៃ៧មករា១៩៧៩ ជាបុណ្យជាតិ គ្រាន់តែយកចិត្តបរទេសមួយប៉ុណ្ណោះ ហើយប្រឆាំងនឹងខ្មែរគ្នាឯង ។ តាមផ្លូវនយោបាយ ទោះបីយ៉ាងណាក៏ដោយ គេត្រូវតែយករូបមន្តបង្រួបបង្រួមជាតិ ជាជាងយកឈ្នះចាញ់គ្នានិងយកចិត្តបរទេសឲ្យខ្មែរនិងខ្មែរបែកបាក់គ្នា ។ ជីវិតមនុស្សកើតមកត្រូវស្លាប់ទៅវិញតាមច្បាប់ធម្មជាតិ ខ្មែររៀមច្បងគួរត្រួសត្រាយផ្លូវឲ្យល្អ ជាមាគ៌ារស់រានមានជីវិតនៃប្រទេសជាមាតុភូមិរបស់ខ្លួន ជាគំរូដ៏ល្អសំរាប់កូនចៅជំនាន់ក្រោយទៀតអនុវត្តតាម ។ ពេលនេះ សូមសំណូមពរតែមួយ គឺឈប់សម្លាប់គ្នា ព្រោះឥឡូវនេះខ្មែរពុឈ្មោះល្បីថា ខ្មែរពូកែសម្លាប់គ្នា សូម្បីអ្នកសារពត៌មានក៏ត្រូវគេលួចសម្លាប់ដែរ ។៚